# ការសម្ភាសរបស់ អ្នកមីងលន់ យឿន

## ក៖ អ្នកដែរសម្ភាស មាសចិន្ដាពិសី ខ៖ អ្នកដែរគេសម្ភាស លន់ យឿន

ក៖ ចាស ចឹងជាដំបូងខ្ញុំសូមជំរាបសួរដល់អ្នកមីង ខ្ញុំអ្នកសម្ភាសឈ្មោះមាសចិន្ដាពិសីមកពីសកលវិទ្យាល័យប្រីហ្គាមយ៉ឹងហៅកាត់ថាប៊ីវ៉ាយយូ មកសម្ភាសពីជីវប្រវត្តិរបស់អ្នកមីងចង់ដឹងថាអ្នកមីងមានឈ្មោះអ្វីហើយចង់ដឹងថាជីវិតរបស់អ្នកមីងមានការលំបាកអ្វីខ្លះពីមួយជំនាន់ទៅមួយជំនាន់ ហើយសព្វថ្ងៃអ្នកមីងមានជីវភាពបែបណាអញ្ចឹងទៅហើយដើម្បីចងក្រងដល់កូនចៅជំនាន់ក្រោយ អោយពួកគាត់អាចបានដឹងដែរថាពីមួយជំនាន់ទៅមួយជំនាន់និងមានការលំបាកអ្វីខ្លះ៕៕ ហើយខ្ញុំសូមបញ្ជាក់ថ្ងៃខែដែរខ្ញុំសម្ភាសអ្នកមីងនៅថ្ងៃទី៥ខែកញ្ញាឆ្នាំ២០១៨នៅភូមិពោធិធំ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្ដាល

ក៖ អ្នកមីង តើអ្នកមីងមានឈ្មោះអ្វីដែរ?

ខ៖ អើរ ខ្ញុំឈ្មោះលន់ យឿន៕

ក៖ កាលពីក្មេងអ្នកមីងមានឈ្មោះណាំដែរហៅក្រៅពីលន់យឿននិងដែរទេអ្នកមីង?

ខ៖ អត់ទេ មានតែឈ្មោះលន់យឿននិងតែមួយ៕

ក៖ ឈ្មោះរបស់អ្នកមីងនិងអ្នកណាជាអ្នកដាក់ងោយដែរអ្នកមីង?

ខ៖ អើរ ឪពុកដាក់អោយ៕

ក៖ អញ្ចឹង!

ខ៖ ចាស៕

ក៖ សព្វថ្ងៃអ្នកមីងមានអាយុប៉ុន្មានដែរហើយ?

ខ៖ អាយុហាសិបហើយ៕

ក៖ ចាស ចឹងអ្នកមីងអាចនៅចាំពីឆ្នាំកំណើតឬក៏ថ្ងៃខែខ្មែរយើងថាអ្នកមីងកើតនៅក្នុងឆ្នាំមួយណាដែរទេ?

ខ៖ ឆ្នាំមួយពាន់ប្រាំបួនរយជិតសិប៕

ក៖ ចុះនៅក្នុងឆ្នាំខ្មែរយើងវិញ តើអ្នកមីងកើតនៅក្នុងឆ្នាំមួយណាអ្នកមីង?

ខ៖ ខ្ញុំអត់បានចាំទេ តែចាំពីឪពុកម្តាយមកគាត់ប្រាប់ថាឆ្នាំរកា មួយពាន់ប្រាំបួនរយជិតសិប៕

ក៖ ចាស អញ្ចឹងទីកន្លែងកំនើតរបស់អ្នកមីងនៅភូមិឃុំស្រុកអ្វីដែរអ្នកមីង?

ខ៖ នៅភូមិតាស្គរ ឃុំតាស្គរ ស្រុកល្វាឯម ខេត្តកណ្តាល៕

ក៖ ហេតុអ្វីបានជាអ្នកមីងផ្លាស់ប្តូរមករស់នៅភូមិពោធិធំសព្វថ្ងៃនេះវិញ?

ខ៖ កាលនិងយើងទៅជំនាន់ប៉ុលពត ទៅគេជម្លៀសមកមកនៅភូមិពោធិធំនិងតែម្តង៕

ក៖ អញ្ចឹងបានន័យថាកាលពីជំនាន់ប៉ុលពតគេបានជម្លៀសគ្រុមគ្រួសាររបស់អ្នកមីងពីភូមិតាស្គរមករស់នៅភូមិពោធិធំនេះវិញ?

ខ៖ ចាស និងហើយ៕

ក៖ នៅពេលដែរគេជម្លៀសអ្នកមីងមករស់នៅភូមិពោធិធំនេះ អ្នកមីងមករស់នៅជាមួយនិងគ្រុមគ្រួសាររបស់អ្នកមីងឬក៏មកនៅតែម្នាក់ឯងទេ?

ខ៖ នៅជាមួយឪពុកនៅជាមួយម្តាយមីងអីនិង៕

ក៖ នៅពេលដែរអ្នកមីងមករស់នៅភូមិពោធិធំនេះគេបានប្រើអោយគ្រួសាររបស់អ្នកមីងបានធ្វើអ្វីខ្លះដែរទេ?

ខ៖ អត់មានបានប្រើអោយធ្វើអីទេ គ្រាន់តែថាយើងធ្វើការងារយើងដាំដុះអីនិងណាធ្វើចំការធ្វើស្រូវអីនិង៕

ក៖ ចុះចំណែកឯការហូបចុកវិញ គេអោយអ្នកមីងហូបចុកបានគ្រប់គ្រាន់ដេរទេ?

ខ៖ ជំនាន់ប៉ុលពត ឬក៏ជំនាន់និងដែរ?

ក៖ ជំនាន់ប៉ុលពតអ្នកមីង!

ខ៖ ហឹម វាអោយយើងហូបបរម្នាក់មួយស្លាបព្រា

ក៖ ចឹងអ្នកមីងមានបងប្អូនចំនួនប៉ុន្មានអ្នកដែរក្នុងគ្រួសារ?

ខ៖ មានពីរ នេះប្អូន៕

ក៖ ចាស ចឹងអ្នកមីងជាកូនបងគេ?

ខ៖ ចាស

ក៖ ប្អូនរបស់អ្នកមីងគាត់មានឈ្មោះអ្វីដែរ?

ខ៖ លន់ ស្រៀង

ក៖ សព្វថ្ងៃគាត់មានអាយុប៉ុន្មានដែរហើយអ្នកមីង?

ខ៖ អាយុ៤៦៕

ក៖សព្វថ្ងៃប្អូនរបស់អ្នកមីងគាត់ប្រកបរបរអ្វីដែរអ្នកមីង?

ខ៖ លក់បាយលក់អីកំប៉ិកកំប៉ុកនិង

ក៖ ចុះកាលពីក្មេងអ្នកមីងបានលេងអ្វីឬក៏ធ្វើអ្វីជាមួយនិងបងប្អូនរបស់អ្នកមីងដែរ?

ខ៖ កាលនុងអើរយើងនៅតូចៗដែរចឹងហា យើងវាភ្លេចដែរចាំតែថាបានពរវាដើរលេងអិតែប៉ុននិង បើថាលើសពីនិងទៀតអត់ចាំទេ៕

ក៖ ចុះចំណែកឯនៅពេលដែរយើងធំៗឡើងចឹងណាអ្នកមីងមានបានទៅលេងនៅឯណាឬក៏ធ្វើអីផ្សេងទៀតពីនិងដែរ?

ខ៖ អើរ វាអត់មានបានទៅណាទេ នៅតែផ្ទះនិង៕

ក៖ ចុះចំណែកឯឪពុកម្ដាយរបស់អ្នកមីងវិញគាត់មានឈ្មោះអ្វីដែរ?

ខ៖ ឈ្មោះលន់ ហឿន

ក៖ ចុះម្ដាយរបស់អ្នកមីងវិញគាត់មានឈ្មោះអ្វីដែរ?

ខ៖ អើរ ម្ដាយគាត់ឈ្មោះយ៉ែម សារឿន៕

ក៖ សព្វថ្ងៃឪពុករបស់អ្នកមីងគាត់មានអាយុប៉ុន្មានដែរហើយ?

ខ៖ អើរ គាត់អាយុហុកជាងហើយ៕

ក៖ អ្នកមីងអាចដឹងពីទីកន្លែងកំណើតរបស់ឪពុកអ្នកមីងដែរទេ?

ខ៖

ខ្ញុំដឹងតែថាទីកន្លែងគាត់នៅភូមិតាស្គរ ស្រុកល្វាឯម ខេត្តកណ្តាលយើងនិងតែម្តងនៅឯនោះនៅឯខាងក្រោមណេ៎ និងភូមិកំណើតគាត់ណា៕

ក៖ ចុះអ្នកមីងអាចដឹងពីឆ្នាំកំណើតរបស់គាត់ ថាតើគាត់កើតនៅក្នុងឆ្នាំដូចជាខាល ថោះ រោង ម្សាញ់អីមួយណាដែរអ្នកមីង?

ខ៖ អត់ដឹង ប៉ុន្តែដឹងតែថាឆ្នាំគាត់រក៕

ក៖ ចាសចឹង ចុះចំណែកឯម្តាយរបស់អ្នកមីងវិញ គាត់មានអាយុប៉ុន្មានដែរហើយសព្វថ្ងៃ??

ខ៖ គាត់ស្លាប់នៅជំនាន់ ប៉ុល បត៕

ក៖ ចាស នៅជេលដែរគាត់ស្លាប់នៅជំនាន់ប៉ុលបតនិង គាត់មានអាយុប៉ុន្មានដែរហើយអ្នកមីង??

ខ៖ អ៊ំ គាត់ស្លាប់ជំនាន់ប៉ុលពតនិង ខ្ទង់ហាសិបហើយ៕

ក៖ ចាស ចុះចឹងទីកន្លែងកំណើតរបស់ម្តាយអ្នកមីងគាត់នៅភូមិឃុំណាដែរ??

ខ៖ នៅភូមិជាមួយតែគ្នានិងនៅភូមិតាស្គរនិង៕

ក៖ ចាស ឪពុករបស់អ្នកមីងគាត់ប្រកបមុខរបរអ្វីសម្រាប់ចិញ្ចឹមក្រុមគ្រួសារដែរអ្នកមីងដែរ?

ខ៖ កាលជំនាន់ប៉ុលពតនិងគេអោយគាត់លើកដី គេអោយគាត់និងទៅធ្វើការនៅសហករសហអីនិងហើយទៅគាត់ឆ្លៀតដាក់លោនដាក់អីបានអីមកយកទៅដូរអង្ករគេហូប យកមកចិញ្ចឹមគ្រួសារអីនិង វេទនាដែរនិងជំនាន់ប៉ុលពតទម្រាំតែយើងបានមកដល់ជំនាន់និងរៀងធូរធារ តែបើជំនាន់នុងយ៉ាប់មែនទែនណា៕

ក៖ ចុះពេលជំនាន់ដែរមិនទាន់បានដល់នោជំនាន់ប៉ុលពតនិង ឪពុករបស់អ្នកមីងគាត់បានធ្វើអ្វីដើម្បីចិញ្ចឹមក្រុមគ្រួសារដែរ?

ខ៖ គាត់ដាក់លោនដាក់អីនិងចេះតែបានទៅ យកទៅដូរអង្ករគេមកចែកអោយគ្រួសារហូបទៅអោយបានថាមួយពេលៗបានរស់ណា ទៅដូរគេបានពីរបីកំប៉ុងទៅយកមកចែកគ្នាហូបទៅ ៕

ក៖ ឪពុករបស់អ្នកមីង គាត់ជាមនុស្សបែបណាដែរទៅអ្នមីង?

ខ៖ គាត់ស្លូតបូតគ្មានកាចអីដូចគេទេ គេគិតតែពីរកចិញ្ចឹមកូនចិញ្ចឹមប្អូនរហូតមកទល់តែគាត់ធ្លាក់ខ្លួន ឥឡូវគាត់ឈឺគាត់ហុកសិបជាងហើយ ៕

ក៖ ចុំណែកឯម្ដាយរបស់អ្នកមីងវិញ កាលគាត់នៅមានជីវិតគាត់ប្រកបរបរអ្វីចិញ្ចឹមគ្រួសារដែរ?

ខ៖ គាត់ត្បាញកន្ទេល ត្បាញកន្ទេលអោយគេទៅបានលុយបន្តិចបន្តួចទៅយកមកទិញសម្ភារះប្រើប្រាស់ ដូចជាអង្ករស្បៀងអីនិងទិញយកមកអោយកូនហូបទៅ បើបានតិចតាមតិចទៅបើបានច្រើនតាមច្រើនទៅចេះតែចែកគ្នាទៅ រស់មួយគ្រាៗទៅ៕

ក៖ ចឹងគាត់អត់បានត្បាញហើយយកទៅលក់អោយឈ្មួញបន្តទេ គាត់ត្បាញអោយគេឬក៏មួយយ៉ាងម៉េចទៀតង្អកមីង?

ខ៖ គាត់ស៊ីឈ្នួញគេនិងដូចថាមួយបានប៉ុន្មានចឹង យើងបានមួយមួយម៉ឺនប្រាំពាន់អីនិង កាលជំនាន់និងមានទៅបានថ្លៃដូចជំនាន់យើងនិងឯណាកាលជំនាន់នុងនៅថោក មួយថ្ងៃអង្គុយមួយថ្ងៃជូនណាបានប្រាំពាន់ ប្រាំពីរពាន់អីនិងតាមតែគេអោយយើងនិង៕

ក៖ អ្នកមីងអាចដឹងថាម្ដាយរបស់អ្នកមីង មួយថ្ងៃគាត់ត្បាញកន្ទេលបានប៉ុន្មានដែរទេ?

ខ៖ ក្នុងមួយថ្ងៃនិងយើងគិតទៅបានពីរ ៕

ក៖ មួយថ្ងៃពេញ?

ខ៖ និងហើយមួយថ្ងៃពេញតាំងពីព្រឹកមកដល់ល្ងាចនិង៕

ក៖ តើម្ដាយអ្នកមីង គាត់ជាមនុស្សបែបណាដែរអ្នកមីង?

ខ៖ គាត់ដូចថាគាត់ស្លូតបូតមិនទៅកោងកាចអីទេ គាត់គិតតែពីធ្វើការងារចិញ្ចឹមកូនទៅ ៕

ក៖ ឪពុកម្ដាយរបស់អ្នកមីង គាត់មានបានធ្លាប់ប្រាប់ពីសាច់រឿងជីវិប្រវត្តិអោយអ្នកមីង ស្ដាប់ដែរទេ?

ខ៖ គាត់អត់មានបានប្រាប់ទេ ប៉ុន្តែគ្រាន់តែយើងដឹងខ្លះៗណាយើងដឹងនិងគាត់មិនបាននិយាយទេយើងដឹងខ្លួនយើងនិងណា បើអោយគាត់ប្រាប់គាត់អត់មានប្រាប់ទេប៉ុន្តែយើងមើលឃើញយើងដឹងថាគាត់ម៉េចអីម៉េចទៅណា៕

ក៖ តើអ្នកមីងនៅចងចាំឈ្មោះជីដូនជីតាខាងម្ដាយរបស់អ្នកមីងដែរទេ?

ខ៖ ខាងម្ដាយឈ្មោះយ៉ែម៕

កៈ លោកតាឬក៏លោកយាយដែរឈ្មោះយ៉ែមនិងង្អកមីង?

ខៈ ឈ្មោះយាយ ហើយនិងអើរតាខាងឪពុកវិញ ឈ្មោះលន់ ចំរើននិងខាងឪពុកបើខាងម្ដាយ យ៉ែម៕

កៈ ចុះលោកតាខាងម្ដាយវិញ គាត់ឈ្មោះធ្វីដែរខាងម្ដាយ?

ខៈ ខាងម្ដាយឈ្មោះយ៉ែមនិងហើយ ឪពុកខាងម្ដាយណាឈ្មោះយ៉ែមបើឪពុកខាងឪពុកឈ្មោះ លន់ ចំរើន ចំរើននិងស្រីណាបើលន់និងប្រុស ៕

កៈ អ្នកមីងអាចដឹងពីទីកន្លែងកំណើតរបស់គាត់ទាំងពីរដែរទេ?

ខៈ កាត់នៅតាស្គរនិងស្រុកកំណើតគាត់ហើយនៅតាស្គរនិង៕

កៈ ហើយចឹងក្រុមគ្រួសាររបស់អ្នកមីងរស់នៅភូមិតាស្គរនេជអស់រយេញពេលយូរហើយមែនទេ ឬក៏ទើបតែមកនៅទេអ្នកមីង?

ខៈ មើលចូរដប់បួនឆ្នាំដប់ប្រាំឆ្នាំហើយចូលមកនៅនិងតាំងពីមួយពាន់ប្រាំបយនរយប៉ែតសិបម កនៅស្រុកនិង និងគេជម្លៀសមកតាំងពីជំនាន់ប៉ុលេពតមកណាគេជម្លៀសមកតាំងពីមួយពាន់ ប្រាំបួនរយប៉ែតសិប៕

កៈ អ្នកមីងចុះចឹង អ្នកមីងមានបងប្អូនដែររស់នៅក្រៅប្រទេសដែរទេអ្នកមីង?

ខៈ អត់ អត់មានទេ៕

កៈ ចាស ទាក់ទងទៅនិងចំណងអាពាហ៍ពិពាហ៍របស់អ្នកមីងវិញ ស្វាមីអ្នកមីងគាត់មានឈ្មោះ អ្វីដែរ?

ខៈ ឈ្មោះ អើរ ស្រ៊ុនស្រឿន

កៈ ស្រ៊ុន ស្រឿនចឹងណាអ្នកមីង?

ខៈ ចាស!

កៈ សព្វថ្ងៃគាត់មានអាយុប៉ុន្មានដែរហើយអ្នកមីង?

ខៈ គាត់អាយុសែសិបប្រាំមួយ៕

កៈ សព្វថ្ងៃស្វាមីអ្នកមីងគាត់ប្រកបរបរអ្វីដែរ?

ខ៖ ហ៊ឹម កសិករយើងនិងធ្វើចំការពេលតំនេរអីនិង

ក៖ ចាស ចឹងតើអ្នកមីងនៅចាំដែរទេថា នៅអំឡុងឆ្នាំណាដែរអ្នកមីងរៀបអាពាហ៏ពិពាហ៏ដែរទេ?

ខ៖ អើរ តាំងពីឆ្នាំពីពាន់ដប់បួន៕

ក៖ នៅពេលដែឬអ្នកមីងរៀបការនិង អ្នកមីងមានអាយុប៉ុន្មានដែរហើយ?

ខ៖ តាំងពីបានគ្នានិងមកខ្ញុំមានអាយុសែសិបប្រាំ៕

ក៖ ចាស ចឹងអ្នកមីងទើបតែរៀបការទេ?

ខ៖ និងហើយ បានប្រហែលបួនប្រាំឆ្នាំនិង៕

ក៖ ចាស និងហើយ ចឹងអ្នកមីងមានកូនចំនួនប៉ុន្មាននាក់ហើយ?

ខ៖ អត់មាន៕

ក៖ អត់មានទេ!!!

ខ៖ ចាស យកគ្នាអត់មានកូនផង មួយនេះក្មួយ៕

ក៖ ចាស ចឹងនៅពេលដែរអ្នកមីងរៀបអាពាហ៏ពិពាហ៏និង ម្តាយរបស់អ្នកមីងជាអ្នករៀបចំដោយឬក៏អ្នកមីងរៀបឡើងដោយខ្លួយនឯងអ្នកមីង?

ខ៖ ឪពុកម្តាយ៕

ក៖ ចាស ចឹងនៅពេលនិងស្វាមីង្អកមីង គាត់បានអោយថ្លៃជំនួនដល់អ្នកមីងប៉ុន្មានដែរទៅ?

ខ៖ បានបន្តិចបន្តួចហា បានប្រហែលប្រាំមួយរយប្រាំពីររយអីនិង៕

ក៖ នៅពេលណាដែរ អ្នកមីងបានជួបគ្នាជាមួយស្វាមីរបស់អ្នកមីងដែរ?

ខ៖ ដោយសារម្តាយមីងស្លាប់ គាត់ស្លាប់ទៅមុនដំបូងខ្ញុំនៅពីរបេព្មនាក់គាត់ដល់អត់ពីគាត់ទៅឪពុកអោយយកគាត់ថាបានពីរនាក់ទៅជួយថែរក្សាគ្នា ដល់អត់ពីគាត់និងទៅបានប្តីនិងថែរក្សាទៅបានយកប្តីនិង៕

ក៖ ចាស ចឹងបានន័យថាកាលពីដំបូង អ្នកមីងបានរស់នៅជាមួយម្តាយមីងរបស់អ្នកមីង?

ខ៖ ចាស និងហើយបើម្ដាយមីងនិងគាត់អត់មានប្ដីទេ៕

ក៖ ម្ដាយមីងរបស់អ្នកមីងនិង គាត់មានឈ្មោះអ្វីដែរអ្នកមីង?

ខ៖ អើរ គាត់ឈ្មោះលន់ ញឹប

ក៖ គាត់ស្លាប់នៅក្នុងឆ្នាំណាដែរអ្នកមីង?

ខ៖ គាត់ស្លាប់ដូចជាពីរពាន់ដប់ពីរ

ក៖ ចាស ចឹងប្រហែលជាគាត់ស្លាប់បានប្រាំមួយឆ្នាំហើយដែរណ៎អ្នកមីង?

ខ៖ បើយើងគិតទៅមើលពីរពាន់ដប់ពីរពីពាន់ដប់បី និងពីឬពាន់ដប់បីនិងគិតទៅបានប្រាំឆ្នាំ៕

ក៖ កាលពីអ្នកមីង នៅក្មេងនិងអ្នកមីងចេះអានសរសេរភាសាខ្មែរយើងបានល្អដែរទេ?

ខ៖ ហឹម រៀនបានតិចនិង រៀនបានត្រឹមថ្នាក់ទីបួននិង៕

ក៖ កាលដែរអ្នកមីងរៀនបានត្រឹមថ្នាក់ទីបួននិង អ្នកមីងរៀននៅសាលាណាដែរអ្នកមីង?

ខ៖ រៀននៅសាលាយើងនិងភូមិពោធិធំនិង

ក៖ កាលអ្នកមីងទៅរៀននិង អ្នកមីងមានលុយចាយគ្រប់គ្រាន់ដែរទេ?

ខ៖ អូយ កាលនុងបានមួយរយពីររយទៅសាលា ប្រាំកាក់មួយកាក់កាលជំនាន់នុងគេចាយមួយកាក់ពីរកាក់ មិនដូចជំនាន់នេះក្មេងមួយសុទ្ធតែបីពាន់យ៉ាងនេះ៕

ក៖ ចាស ចឹងសព្វថ្ងៃអ្នកមីងមានមិត្តភក្ដីដែរធ្លាប់រៀនជាមួយគ្នានិងដែរទេអ្នកមីង?

ខ៖ មានពីរបីនាក់អីដែរនិង ប៉ុន្តែគេមានប្ដីអីអស់ហើយ៕

ក៖ មិត្តភក្តិរបស់អ្នកមីង គាត់នៅភូមិឃុំណាដែរ?

ខ៖ នៅជាមួយគ្នានិង អ្នកខ្លះគេកូនពីឬកូនបីកូនបួនអីអស់ហើយ៕

ក៖ កាលពីអ្នកមីងទៅរៀននិង អ្នកមីងបានអ្វីសម្រាប់ធ្វើជាមធ្យោបាយធ្វើដំណើរឬក៏ទៅជាមួយនិងមិត្តភក្តិរបស់អ្នកមីងដែរ?

ខ៖ ដើរ ពីនិងទៅដល់សាលាពោធិធំនោះ ដើររហូតទៅគ្មានអីជិះទេមានតែដើរ៕

ក៖ កាលដែរអ្នកមីងនៅរៀននិង អ្នកមីងចូលចិត្តលេងអ្វីជាមួយនិងមិត្តភក្តិរបស់អ្នកមីងដែរ?

ខ៖ លោតអន្ទាក់ ហើយនិងមួយទៀតអាគេដាក់កៅស៊ូហើយគេធ្វើញេះនោះ

ក៖ អ៎ លេងហោះកម្ពស់និងមែនអ្នកមីង?

ខ៖ និងហើយ មានណាមុខមាត់ទ្វាសាលានិងជាន់លោតនៅនិង៕

ក៖ ចឹងកាលពីក្មេងអ្នកមីង ពូកែលេងលោតកៅស៊ូដែរអ្នកមីង?

ខ៖ បានតែត្រឹមនេះតែបាន តែបើប៉ុននេះអត់បានទេ ទាល់តែធាក់អីអាជណ្ដើរនោះទៅឡើងចង់ក្រេចជើង៕

ក៖ ចាស នៅក្នុងជីវិតរបស់អ្នកមីងវិញ តើអ្នកមីងបានធ្វើការអ្វីខ្លះដែរ?

ខ៖ ធ្វើចំការនិង ជួលដីគេធ្វើ៕

ក៖ ចុះអ្នកមីងធ្លាប់បានទៅស៊ីឈ្នួលគេ បេះផ្លែឈើត្បាញកន្ទេលអីដែរទេ?

ខ៖ ជួនកាលផុតពីការងារយើងនិង យើងទៅធ្វើព្រៃអោយគេទៅបានមួយថ្ងៃពីរពាន់៕

ក៖ ជីវិតរបស់អ្នកមីងតាំងពីក្មេងមកដល់ពេលឥឡូវនេះ មានការផ្លាស់ប្ដូរអ្វីខ្លះដែរទេ?

ខ៖ ហាត់នឿយច្រើនណាស់បើយើងមិនខំប្រឹងមានតែអត់ អ្វើទៅជួលដីគេទៅចឹងបានថាកាលនៅក្មេងយើងធ្វើការធ្ងន់ពេក មកដល់វ័យប៉ុននិងយើងឈឺរហូតអត់សូវធ្វើការអីបានទេមាំទេ៕

ក៖ អ្នកមីងកាប់ព្រៃអោយគេឬមួយធ្វើយ៉ាងម៉េចដែរអ្នកមីង?

ខ៖ អត់ទេគ្រាន់ថាយើងទៅជួលដីគេចឹងណា យើងអត់ទាន់មានប្ដីណាជួលដីគេចឹងទៅទុយោយើងនិងហាសិបដើមអីនិងយើងលីតែម្នាក់ឯង បើម្ដាយមីងឈឺគាត់ឈឺធ្ងន់គាត់ធ្វើអីអត់កើតហាហុកសិបដើមនិងយើងលីទៅទម្រាំតែទៅដល់ចំការ ហើយមកដល់វ័យប៉ុននិងយើងឡើងបាក់៕

ក៖ នៅពេលដែរអ្នកមីងរស់នៅជាមួយនិងម្ដាយមីងរបស់អ្នកមីងនិងកាលនិងអ្នកមីងមានអាយុប៉ុន្មានដែរ?

ខ៖ តាំងពីអាយុដប់ប្រាំឆ្នាមកដល់អាយុសែជាង៕

ក៖ យូរឆ្នាំដែរអ្នកមីង អស់សែសិបឆ្នាំជាងហើយ៕

ខ៖ និងហើយ៕

កៈ បន្ទាប់ពីអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ហើយជីវិតរបស់អ្នកមីងមានភាពសុខស្រួលដែរទេ?

ខៈ គ្រាន់តែថាវារៀងធូរបន្តិច អាការងាស្រោលធូន់អីនិងបានប្ដីជួយយើងចឹងណា បើកាលយើងអត់ទាន់មានប្ដីអាការងារធូន់ៗចឹងយើងពាំងមុខខ្លួនឯងចឹងណា យើងខ្លួយនឯងទាំងអស់បើគាត់ធ្វើការអត់កើតដូចយើងមេគ្រួសារគាត់ចឹង៕

កៈ ចុះចំណែកឯចំណង់ចំណូលចិត្តរបស់អ្នកមីងវិញ តើអ្នកមីងចូលចិត្តបរិភោគអាហារអ្វីដែរ?

ខៈ អឹម ស្លរម្ជូរប្រហើ ចំណូលជាងគេតែពីរមុខនិង៕

កៈ ចុះការច្រៀងការស្ដាប់ចម្រៀងអីអ្នកមីងចូលចិត្តដែរទេ?

ខៈ អាយើងច្រៀងខ្លួនឯងនិងឃើញគេច្រៀងខារ៉ាអូខេរាល់ថ្ងៃនិងអត់ចេះទេ បើប៉ុនណាស់បានតែមួយបទអីនិង៕

កៈ ចុះការរាំអីនិង អ្នកមីងចូលចិត្តដែរទេ?

ខៈ កាលយ៉ងនៅជាមួយម្ដាយមីងនិង បេលយើងលេងទៅយើងគិតគាត់ថាគាត់ឈឺពេលយើងទៅលេងអញ្ជឹងក៏ចិត្តយើងមិនសប្បាយចិត្តដែរបើគាត់ឈឺ ដល់ទៅពេលគាត់ស្លាប់ចឹងទៅយើងបានលេងដូចថាអារម្មណ៍យើងអត់គិតណាបើពីមុនពេលយើងលេងចឹងទៅអត់សប្បាយចិត្តដល់ពេលគាត់ស្លាប់ចឹងទៅដូចថាយើងមានប្ដីមានអីចឹងទៅងារម្មណ៍យើងគិតផ្សេងចឹងទៅនោជាមួយគាត់យូរទៅគិតសព្វ៕

កៈ នៅពេលដែរម្ដាយមីងរបស់អ្នកមីងស្លាប់ទៅចឹង ការកាប់ព្រៃការត្បាញការស៊ីឈ្នួលគេអីនិង ហើយកម្លាំងរបស់អ្នកមីងដែរធ្លាប់តែធ្វើការធូន់អីមានការធូរស្រោលអីបានខ្លះដែរទេអ្នកមីង?

ខៈ បានធូរដូចថាយើងទៅធ្វើការចឹងយើងអត់គិតគាត់ណា តាំងពីគាត់ស្លាប់ទៅនិងដូចថាយើងមានប្ដីនិងពីរនាក់ប្ដិនិងផ្ទក់ដីគ្នារកស៊ីចឹងទៅ៕

កៈ នៅក្នុងក្រុមគ្រួសាររបស់អ្នកមីង តើមានសមាជិកណាដែរគាត់ចេះលេងឧបករណ៍ភ្លេងខ្មែរដូចជារនាត អញ្ជឹងដែរទេអ្នកមីង?

ខៈ អឹម មានតែក្មួយកូនវានោះចេះវាចុចកំព្យូទ័រ ហើយកូនវាមីស្រីមួយមិញនិងគ្រូបង្រៀនសិស្ស៕

កៈ ចាស ចឹងគាត់ធ្វើជាគ្រូបង្រៀនបឋមសិក្សាឬក៏មធ្យមសិក្សាដែរអ្នកមីង?

ខ៖ បង្រៀនក្មេងតូចៗនិងអាយុប្រហែលបួនប្រាំឆ្នាំនិង៕

ក៖ ផ្ទះរបស់អ្នកមីងកាលពីសម័យសង្គមមានលក្ខណះបែបណាដែរអ្នកមីង?

ខ៖ ដូចតែគេដូចតែឯងនិង យើងកាលជំនាន់នុងផ្ទះប៉ុនរបងស្វាយនោះនិង៕

ក៖ ផ្ទះប្រកស្បូវឬក៏យ៉ាងណាដែរអ្នកមីង?

ខ៖ អើរ ស្បូវសសរដើមស្លាយើងនិង ដើមស្លាដើមឬស្សីនិងផ្ទះចេះតែបាននៅនៅនិងគេទៅមិនដូចគេឯណាផ្ទះឈើអីណា ផ្ទះមីងនិងផ្ទះសសរឫស្សីដើមស្លានិងចេះតែធរីទៅហើយនិងប្រកស្លឹក៕

ក៖ នៅក្នុងជីវិតរបស់អ្នកមីង តើអ្នកមីងបានជួបនិងឧបសគ្គអ្វីខ្លះដែរ?

ខ៖ បញ្ហានៅពេលដែរយើងមិនខំប្រឹងទៅរកទៅវាអត់ ចឹងទៅយើងខំប្រឹងទៅរកទៅដូចថាយើងនៅផ្ទះនិងមិនធ្វើអីយើងចេះតែធ្វើទៅ៕

ក៖ កាលពីអ្នកមីងនៅក្មេងវិញ តើអ្នកមីងធ្លាប់ស្រមៃថាចង់ធ្វើអ្វីមួយនៅពេលធំឡើងដែរទេ??

ខ៖ ជីវិតយើងពិបាកចឹងចេះតែគិតធ្វើទៅបើមិនធ្វើវាអត់៕

ក៖ ដូចជាអ្នកមីងស្រមៃថាធំឡើងអ្នកមីងចង់ធ្វើជាគ្រូបង្រៀន ពេទ្យអ្វីមួយនៅពេលធំឡើងនិងដែរទេអ្នកមីង?

ខ៖ អត់ ស្រមៃអីទេបើយើងខ្វះជីវភាពមិនដូចគេឯណា ធ្វើម៉េចថាអោយតែធ្វើការងារបានលុយតែប៉ុននិង៕

ក៖ ចាស ចឹងចុងក្រោយតើអ្នកមីងមានអ្វីផ្តាំផ្ញើរដល់កុនចៅជំនាន់ក្រោយអោយពួកគាត់ខំប្រឹងប្រែងរៀនសូត្រអីចឹងដែរទេអ្នកមីង?

ខ៖ ចាស និងហើយគ្រាន់តែយើងបានប្រាប់ថាអោយក្មួយៗនិងខំប្រឹងរៀនទៅអោយវាបានធូរកម្លាំងកុំដូចជំនាន់អ៊ុំចេញតែពលកម្មហាត់ បើចេះទៅធ្វើការនៅមួយមន្លែងចឹងទៅធូរខំប្រាប់វាថាកុំអោយធ្វើដូចអ៊ុំចឹងអ៊ុំចេញហាលក្តៅចឹងអត់មានតំរិះអីនិងគេ៕

ក៖ ចាស ចឹងខ្ញុំសូមអរគុណដល់អ្នកមីងដែរបានចំណាយពេលអោយខ្ញុំសម្ភាសពីជីវប្រវត្តិរបស់អ្នកមីង ហើយខ្ញុំសូមថតរូបអ្នកមីងសទុកជាអានុស្សាវរីយមួយ ហើយថាតើអ្នកមីងអនុញ្ញាតអោយក្មួយយកម្លេងរបស់អ្នកមីងដាក់ចូលនិងកេហទំព័ររបស់សាលាបានដែរទេ?

ខ៖ មានអីបានតើ៕

ក៖ ចាស ចឹងក្អួយអរគុណច្រើន៕